## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

ថ្ងៃអង្គារ ៥កើត ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០២១

### សេចក្តីជូនដំណឹង
### ស្តីពី
### ការកែសម្រួលអត្រាអាករពិសេសលើមុខទំនិញរថយន្តមួយចំនួន

អនុលោមតាមអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពីការកែសម្រួលអត្រាអាករពិសេសលើមុខទំនិញមួយចំនួន អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា មានកិត្តិយស សូមជម្រាបជូនវិនិយោគិន ធុរជន និងភាគីពាក់ព័ន្ធទាំងអស់ ជ្រាបថា រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបញ្ចុះអត្រាអាករពិសេស លើមុខទំនិញរថយន្តមួយចំនួន ដែលនឹងចូលជាធរមានចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ នេះតទៅ។

អាស្រ័យហេតុនេះ ចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ នេះតទៅ ការនាំចូលរថយន្តគ្រួសារ, រថយន្តដឹកទំនិញមួយចំនួន និងរថយន្តដឹកអ្នកដំណើរប្រភេទប្រើអគ្គិសនីសុទ្ធ ដូចមានចែងក្នុងអនុក្រឹត្យខាងលើ នឹងត្រូវជាប់កាតព្វកិច្ចពន្ធអាករកែសម្រួលថ្មី **ដោយគិតតាមកាលបរិច្ឆេទនៃការចុះបញ្ជិកាប្រតិវេទន៍គយ**។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងតាមទូរស័ព្ទលេខ 012 263 537, 070 507 705 និង 010 324 656។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន ធុរជន និងភាគីពាក់ព័ន្ធទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាព។

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

អាសយដ្ឋាន: លេខ ៦-៨ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ / ទូរសារ: (៨៥៥-២៣) ២១៤ ០៦៥ / ៧២៥ ១៨៧ / ២១២ ៤៥៧ / E-mail: info-pru@customs.gov.kh

## តារាងសង្ខេប ស្តីពី ការកែសម្រួលអត្រាអាករពិសេសលើរថយន្តមួយចំនួន

### I.រថយន្តគ្រួសារ

<table>
<tr><th rowspan="3">ប្រភេទថាមពល / ទំហំស៊ីឡាំង</th><th colspan="2">សាំងសុទ្ធ</th><th colspan="2">ម៉ាស៊ូតសុទ្ធ</th><th colspan="2">Hybrid</th></tr>
<tr><th colspan="2">អត្រាអាករពិសេស (%)</th><th colspan="2">អត្រាអាករពិសេស (%)</th><th colspan="2">អត្រាអាករពិសេស (%)</th></tr>
<tr><th>អត្រាចាស់</th><th>អត្រាថ្មី</th><th>អត្រាចាស់</th><th>អត្រាថ្មី</th><th>អត្រាចាស់</th><th>អត្រាថ្មី</th></tr>
<tr><td>មិនលើសពី 1000 cc</td><td>30</td><td>20</td><td rowspan="2">60</td><td rowspan="3">50</td><td>30</td><td>20</td></tr>
<tr><td>លើសពី 1000 cc ដល់ 2500 cc</td><td rowspan="3">60</td><td rowspan="3">50</td><td rowspan="3">60</td><td rowspan="3">50</td></tr>
<tr><td rowspan="2">លើសពី 2500 cc ដល់ 3000 cc</td><td>60*</td></tr>
<tr><td>70**</td><td rowspan="2">55</td></tr>
<tr><td>លើសពី 3000 cc</td><td>70</td><td>55</td><td>70</td><td>65</td><td>50</td></tr>
</table>

**សម្គាល់÷**

-រថយន្តលីម៉ូហ្ស៊ីនវែងគ្រប់ប្រភេទ ក្រៅពីប្រភេទប្រើថាមពលអគ្គិសនីសុទ្ធ ត្រូវបានបញ្ចុះពីអត្រាអាករពិសេសពី **៧០%** មក **៥៥%**

-*រថយន្តដែលមានទំហំស៊ីឡាំងលើសពី 2500cc ដល់ 3000cc ប្រើថាមពលប្រេងម៉ាស៊ូត(លើកលែងតែរថយន្តផ្ទុះគ្រប់ប្រភេទ និងរថយន្ត ភ្ជុំដំឡើងរួចប្រភេទ 2WD ក្រៅពីសេដាន)

-**រថយន្តដែលមានទំហំស៊ីឡាំងលើសពី 2500cc ដល់ 3000cc ប្រើថាមពលប្រេងម៉ាស៊ូត ជាប្រភេទរថយន្តផ្ទុះ និងរថយន្តភ្ជុំដំឡើងរួចប្រភេទ 2WD (ក្រៅពីសេដាន) ។

| II. **រថយន្តប្រើអគ្គិសនីសុទ្ធ** | អត្រាអាករពិសេស (%) | |
|---|---|---|
| | អត្រាចាស់ | អត្រាថ្មី |
| រថយន្តគ្រួសារនិងរថយន្តដឹកអ្នកដំណើរ | 30 | 10 |

| III. **រថយន្តដឹកទំនិញ** | អត្រាអាករពិសេស (%) | |
|---|---|---|
| | អត្រាចាស់ | អត្រាថ្មី |
| រថសណ្តោងសម្រាប់សីមីរ៉ឺម៉ក | 40 | 25 |
| រថយន្តដឹកទំនិញដែលមានទម្ងន់សរុប(ទម្ងន់រថយន្ត+ទម្ងន់ផ្ទុក) Gross Vehicle Weight > 5 តោន | 40 | 30 |

| IV. **រថយន្តបែន រថយន្តស្ទូច និងរថយន្តឯកទេសផ្សេងទៀត** | អត្រាអាករពិសេស (%) | |
|---|---|---|
| | អត្រាចាស់ | អត្រាថ្មី |
| រថយន្តបែន រថយន្តស្ទូច រថយន្តខ្វង រថយន្តលាយបេតុង រថយន្តផលិតកម្ម គ្រឿងរំសេវផ្ទុះចល័ត និងប្រភេទប្រហាក់ប្រហែលផ្សេងទៀត | 40 | 30 |

*(យោងអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២១ ស្តីពី ការសម្រួលអត្រាអាករពិសេសលើមុខទំនិញរថយន្តមួយចំនួន ដែលនឹងត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១)*